## រឿងទី៤៖ ប្រាក់ពីរសេនរបស់ស្ត្រីមេម៉ាយ

**ខគម្ពីរ៖ ម៉ាកុស១២:៤៣**

ព្រះយេស៊ូត្រាស់ហៅពួកសិស្សមក ហើយមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាបានដឹងច្បាស់ថា ស្ត្រីមេម៉ាយក្រីក្រនេះបានដាក់ប្រាក់ក្នុងហិបច្រើនជាងគេទាំងអស់

មានថ្ងៃមួយ ព្រះយេស៊ូវ និងសាវកទាំងអស់បានធ្វើដំណើរទៅព្រះវិហារ។ ព្រះយេស៊ូបានបានអង្គុយនៅក្នុងព្រះវិហារ ទតមើលមនុស្សទាំងអស់កំពុងដាក់តង្វាយថ្វាយដល់ព្រះជាម្ចាស់។ នៅចំណោមមនុស្សជាច្រើន ទ្រង់ទតឃើញអ្នកមានដ៏មានអំនួតម្នាក់ចេញមកខាងមុខដើម្បីដាក់ប្រាក់តង្វាយ។

អ្នកមាននោះ បានដកប្រាក់ចេញពីក្នុងហោប៉ៅយ៉ាងច្រើនចេញមក ឱ្យមនុស្សជាច្រើនឃើញ។

រួចក៏ដាក់ប្រាក់នោះទៅក្នុងហិបតង្វាយ។ បន្ទាប់មក មានមេម៉ាយក្រីក្រស្លៀកសម្លៀកបំពាក់ចាស់រហែកម្នាក់បានចូលមកដាក់តង្វាយ។

នៅជុំវិញនោះមានមនុស្សជាច្រើនដែរ ប៉ុន្តែគ្មានអ្នកណាម្នាក់សម្លឹងមើលទៅស្ត្រីម្នាក់នោះសោះ។

ស្ត្រីនោះបានដាក់ប្រាក់ពីរសេនដែលគាត់បានត្រៀមមកយ៉ាងអស់ពីចិត្ត ចូលក្នុងហិបតង្វាយ។

ប្រាក់ពីរសេនដែលស្ត្រីនោះបានដាក់ បើគិតជាប្រាក់រៀលវិញ ប្រហែលជាខ្ទង់ ៨០០ ទៅ១០០០រៀលតែប៉ុណ្ណោះ។

ពេលសម្លេងប្រាក់កាក់ដែលស្ត្រីនោះបានដាក់ក្នុងហិបលាន់ឡើងភ្លាម មនុស្សដែលនៅជុំវិញក៏ចាប់ផ្តើមសើចចំអកដល់ស្ត្រីនោះ។

នៅពេលនោះ គឺមានម្នាក់កំពុងតែទតមើលពួកគេយ៉ាងស្ងៀមស្ងាត់។

ហើយអ្នកនោះ គឺជាព្រះយេស៊ូ ព្រះយេស៊ូបានហៅពួកសាវកទាំងអស់មក ហើយមានបន្ទូលថា៖ «ស្ត្រីមេម៉ាយក្រីក្រនេះ បានដាក់ប្រាក់ច្រើនជាងអ្នកមានដែលដាក់តង្វាយមុនគេនោះទៅទៀត»។ ពួកសាវកទាំងអស់ក៏សួរទ្រង់ថា៖ «ហេតុអ្វីបានជាទ្រង់មានបន្ទូលដូច្នេះទៅវិញ? ដ្បិតអ្នកមាននោះបានដាក់ប្រាក់យ៉ាងច្រើនថ្វាយដល់ព្រះជាម្ចាស់ ប៉ុន្តែស្ត្រីមេម៉ាយនោះវិញ ថ្វាយតែពីរសេនទេ»។

ព្រះយេស៊ូក៏មានបន្ទូលឆ្លើយទៅពួកសាវកវិញថា៖ «ដ្បិតអ្នកមាននោះបានថ្វាយប្រាក់តែបន្តិចប៉ុណ្ណោះ ក្នុងចំណោមប្រាក់ជាច្រើនដែលគេមាន ប៉ុន្តែស្ត្រីនោះវិញ បានថ្វាយប្រាក់ទាំងអស់របស់នាងដល់ព្រះជាម្ចាស់វិញ។»។ព្រះជាម្ចាស់ទ្រង់មិនទតមើលមនុស្សតែពីសម្បកក្រៅទេ។ ហើយទ្រង់ក៏មិនទតមើលថាមនុស្សបានដាក់តង្វាយប៉ុន្មានដែរ។

ប៉ុន្តែ ព្រះជាម្ចាស់ទ្រង់ទតមើលតែដួងចិត្តរបស់មនុស្ស ថាពួកគេស្រឡាញ់ទ្រង់ប៉ុនណា ហើយមានចិត្តស្មោះត្រង់ចំពោះប្រាក់ តង្វាយនោះតែប៉ុណ្ណោះ។



- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(ម៉ាកុស១២:៤៣)

ស្ត្រីមេម៉ាយក្រីក្រនេះបានដាក់ប្រាក់ក្នុងហិបច្រើនជាងគេទាំងអស់

**សកម្មភាពទី១** សូមគិតពីមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



**សកម្មភាពទី២**

ស្ត្រីមេម៉ាយក្រីក្រ បានត្រៀមដង្វាយមកថ្វាយដល់ព្រះជាម្ចាស់យ៉ាងអស់ពីចិត្ត។
តើកូនៗទាំងអស់គ្នា អាចថ្វាយអ្វីខ្លះ ដល់ព្រះជាម្ចាស់? សូមគូររូបដង្វាយរបស់ខ្លួននៅក្នុងកន្ត្រកដង្វាយ។

